ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍បាត់ដំបង

សភាព្រហ្មទណ្ឌ

-សំណុំរឿងលេខ: ៤៤

-ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១

-សាលដីកាលេខ: ១៥៣ "ឃ"

-ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១

# សាលដីកា

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍បាត់ដំបង

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។

បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍បាត់ដំបង នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ០៨ និង ០០ នាទីព្រឹក ជាន់ទី១ សាលសវនាការទី១ ដោយមានសមាសភាពដូចខាងក្រោម៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជីសាលាឧទ្ធរណ៍បាត់ដំបង

ដើម្បីជំនុំជម្រះបណ្តឹងឧទ្ធរណ៍លើសំណុំរឿងសភាព្រហ្មទណ្ឌលេខ: ៤៤ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង ដែលមាន៖

ជនជាប់ចោទឈ្មោះ [redacted] **ទិន** ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរជាងភ្លើង ទីកន្លែងកំណើតភូមិសុវណ្ណសាគរ ឃុំកំពង់កណ្តាល ស្រុកកំពង់បាយ ខេត្តកំពត ទីលំនៅមុនពេលចា[redacted] សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ[redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០២នាក់ កម្រិតវប្បធម៌ថ្នាក់ទី០៣ ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារពីបទលួច ។ (ក្នុងឃុំ)

ជាប់ចោទពីបទ រំលោភសេពសន្ថវៈស្ថានទម្ងន់ទោស (ដោយមូលហេតុអាយុជនរងគ្រោះ) ប្រព្រឹត្ត នៅភូមិក្បាលស្ពាន២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលអំឡុងខែឧសភា ឆ្នាំ២០២០ តាមមាត្រា២៣៩ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

ដោយមានលោក [redacted] សុខា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

ជនរងគ្រោះឈ្មោះ [redacted] ចន្ទា ហៅ អាធី ភេទស្រី អាយុ១០ឆ្នាំ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ថុល ភេទស្រី អាយុ៤០ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋានភូមិក្បាលស្ពាន២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

-បានឃើញ ដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះលេខ: ៤៤ ព្រទ.ឧបប/២១ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ របស់ប្រធានសាលាឧទ្ធរណ៍បាត់ដំបង ។

**-បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ទិន សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: **១២៣ (គ)/១០៧៥** ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ គ្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច ។

**-បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ: **១២៣ (គ)/១០៧៥** ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

**-បានឃើញ** របាយការណ៍រឿងសភាព្រហ្មទណ្ឌ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង ។

**-បានឃើញ** សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ របស់មហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ។

## អំពីអង្គហេតុសង្ខេបមានដូចតទៅ

កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ វេលាម៉ោង១៩ និង០០នាទី នៅចំណុចភូមិក្បាលស្ពាន២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មានករណី រំលោភសេពសន្ថវៈ មួយកើតឡើងប្រព្រឹត្តដោយជនល្មើសឈ្មោះ [redacted] វិន ភេទប្រុស អាយុ២៤ឆ្នាំ បានធ្វើសកម្មភាពចាប់រំលោភក្មេងស្រីឈ្មោះ [redacted] ចិន្តា ហៅ **អាទី** ភេទស្រី អាយុ១០ឆ្នាំ ខណៈពេលដែលម្តាយក្មេងស្រីមិននៅផ្ទះ ដោយឃើញឱកាសល្អជនល្មើសឈ្មោះ [redacted] **វិន** ក៏បានចាប់ក្មេងស្រីឈ្មោះ [redacted] ចិន្តា ហៅ **អាទី** ស្រាតខោអាវអស់ និងឱ្យនាង [redacted] ហើយបានយកម្រាមដៃល្ងូកលែង [redacted] ក្រោយមកក៏បានយក [redacted] ហៅ **អាទី** ដែរ និងបានយ [redacted] ហើយបាន [redacted] ចិន្តា ហៅ **អាទី** បានប្រហែលមួយ ភ្លេតក៏ដកចេញ ។ ក្រោយពីបានទទួលពាក្យបណ្តឹងពីម្តាយជនរងគ្រោះឈ្មោះ [redacted] ថុល ភេទស្រី អាយុ៤០ឆ្នាំ សមត្ថកិច្ចបានចុះស្រាវជ្រាវ និងឃាត់ខ្លួនជនល្មើសឈ្មោះ [redacted] វិន មកកាន់អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធី ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសលើជនជាប់ចោទកំណត់ ១០ (ដប់)ឆ្នាំ ហើយជនជាប់ចោទបានដាក់ពាក្យប្តឹងឧទ្ធរណ៍ ។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង

-ជនជាប់ចោទឈ្មោះ [redacted] ទិន បានឆ្លើយថា: ខ្លួនទទួលស្គាល់ចំពោះអង្គហេតុខាងលើ ប៉ុន្តែវាមានលក្ខណៈធ្ងន់ធ្ងរពេក ។ ខ្លួនមិនបានធ្វើសកម្មភាពរំលោភសេពសន្ថវៈលើក្មេងទេ គឺខ្លួនបានត្រឹមតែប៉ះប្រដាប់ភេទនាង ហើយក៏មិនបានឱ្យនាងស្រាតខោអាវ [redacted] នាងនោះទេ ។ ជនរងគ្រោះគឺជាកូនចុងរបស់ខ្លួន មូលហេតុដែលនាំឱ្យមានការចោទប្រកាន់ខ្លួននោះមកពីខ្លួនទៅប៉ះប្រដាប់ភេទរបស់ជនរងគ្រោះ ។ ខ្លួនទទួលស្គាល់ចម្លើយដែលបានឆ្លើយនៅដំណាក់កាលនាការសាលាដំបូងខេត្តបន្ទាយមានជ័យ ដោយគ្មានការបង្ខិតបង្ខំនោះទេ ។

-អំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] ចន្ថា ហៅ អាទី បានឆ្លើយថា: កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ ឈ្មោះ [redacted] វិន ដែលជាឪពុកចុងរបស់ខ្លួន បានឱ្យខ្លួ [redacted] ប្រដាប់ភេទរបស់ខ្លួន ដោយខ្លាចម្តាយខ្លួនមកទាន់ ក៏បញ្ឈប់សកម្មភាព ។ ក្រោយមកខណៈពេលម្តាយខ្លួនមិននៅផ្ទះ ពេលខ្លួនចូលបន្ទប់ទឹកឈ្មោះ [redacted] វិន បានមកចាប់ស្រាតខោអាវអស់ រួចបានយកប្រដាប់ភេទរបស់គាត់មក [redacted] ទជាខ្លាំង ។

-អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ថុល បានឆ្លើយថា: កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២០ កូនស្រីរបស់ខ្លួនឈ្មោះ [redacted] ចិន្តា ហៅ អាទី អាយុ១០ឆ្នាំ បាននិយាយប្រាប់ខ្លួនថា ឈ្មោះ [redacted] វិន (ប្តីចុងរបស់ខ្លួន) បាន [redacted] ហើយឈ្មោះ [redacted] វិន បានយក [redacted] របស់កូនស្រីរបស់ខ្លួនឈ្មោះ [redacted] ចិន្តា ហៅ អាទី ចំនួនពីរលើក ខណៈខ្លួនកំពុងទៅធ្វើការបាត់ ។ លើកទី១ កាលអំឡុងខែឧសភា ឆ្នាំ២០២០ ឈ្មោះ [redacted] វិន បានហៅកូនស្រីខ្លួនឈ្មោះ [redacted] ចិន្តា ហៅ អាទី ឱ្យឡើងទៅលើឡៅតឿក្នុងផ្ទះ ហើយឱ្យកូ [redacted] ចិន្តា ហៅ អាទី ។ លើកទី២ ពេលកូនស្រីរបស់ខ្លួនឈ្មោះ [redacted] ចិន្តា ហៅ អាទី ចូលក្នុងបន្ទប់ទឹកឈ្មោះ ណា វិន ចូលទៅតាម ហើយបានចាប់ដោះខោអាវកូនស្រីខ្លួនឈ្មោះ [redacted] ចិន្តា ហៅ អាទី និង [redacted] ក្រោយពេលខ្លួនឮដូច្នេះក៏ទៅដាក់ពាក្យបណ្តឹងតែម្តង ។ សំណូមពរនៅក្នុងរឿងនេះខ្លួនមិនទាមទារសំណងទេ ។

-សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ: ក្រោយពីបានពិនិត្យសំណុំរឿង ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ អំណានចម្លើយរបស់ជនរងគ្រោះ អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងនានា តំណាងមហាអយ្យការប្តឹងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់ និងសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ: ក្រោយពីបានពិនិត្យសំណុំរឿង ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ អំណានចម្លើយរបស់ជនរងគ្រោះ អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងនានា ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ខ្លួនយល់ឃើញថា តាមអង្គហេតុ និងចម្លើយរបស់ជនជាប់ចោទ ចម្លើយជនរងគ្រោះ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឃើញថាអង្គហេតុជាក់ស្តែងមិនបានប្រើប្រាស់អំពើហិង្សាណាមួយដែលពាក់ព័ន្ធនឹងខ្លឹមសារនៃមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌនោះទេ ទាក់ទងនឹងការចោទប្រកាន់ខ្លួនស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាកែប្រែបទចោទ ទៅជាបទ រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំវិញ តាមមាត្រា ៣២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ម្យ៉ាងវិញទៀតជន

ជាប់ចោទរូបនេះគឺជាជនមានការអប់រំទាប់ ដូច្នេះការប្រព្រឹត្តរបស់គេគឺធ្វើឡើងដោយមិនបានពិចារណាគ្រប់ជ្រុងជ្រោយ បន្ទាប់ពីរូបគេបានប្រព្រឹត្តអំពើនេះរូបគេបានដឹងអំពីកំហុសរបស់គេ ដូច្នេះខ្លួនស្នើសុំឱ្យក្រុមប្រឹក្សាបន្ធូរបន្ថយទោសឱ្យកូនក្តីរបស់ខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-យល់ឃើញថា: ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ទិន សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: **១២៣ (គ)/១០៧៥** ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច បានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលបណ្តឹងនេះបានធ្វើឡើងត្រឹមត្រូវតាមទម្រង់ និងរយៈពេលដែលច្បាប់បានកំណត់ ដែលនាំឱ្យសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បាត់ដំបង មានសមត្ថកិច្ចអាចលើកយកមកធ្វើការជំនុំជម្រះ និងសម្រេចសេចក្តីតាមនីតិវិធីបានស្របតាមមាត្រា ៣៧៣ មាត្រា ៣៧៤ មាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៨២ (ថ្មី) នៃច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា: សាលាដំបូងខេត្តបន្ទាយមានជ័យ បានចេញសាលក្រមព្រហ្មទណ្ឌលេខ: **១២៣ (គ)/១០៧៥** ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ ដោយបានសម្រេចសេចក្តីដូចតទៅ៖១.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] រិន ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ កំណត់ដាក់ពន្ធនាគារកំណត់រយៈពេល ១០ (ដប់)ឆ្នាំ ពីបទ: រំលោភសេពសន្ថវៈ ស្ថានទម្ងន់ទោស (ដោយមូលហេតុអាយុជនរងគ្រោះ) ប្រព្រឹត្តនៅចំណុចភូមិក្បាលស្ពាន២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ តាមមាត្រា **២៣៩** និងមាត្រា **២៤១** នៃក្រមព្រហ្មទណ្ឌ ។ សាលក្រមនេះជំនុំជម្រះជាអសាធារណៈនាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ និងប្រកាសជាអសាធារណៈនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

៣-យល់ឃើញថា: ជនជាប់ចោទ បានប្តឹងនឹងសេចក្តីសម្រេចទាំងមូល នៃសេចក្តីសម្រេចដោយលើកមូលហេតុថា ការសម្រេចរបស់សាលាដំបូងខេត្តបន្ទាយមានជ័យ ពុំមានភាពយុត្តិធម៌ ដោយហេតុថាខ្លួនមិនបានរំលោភសេពសន្ថវៈលើក្មេងនោះទេ ។

៤-យល់ឃើញថា: នាពេលសវនាការប្រធានក្រុមប្រឹក្សាជំនុំជម្រះបានអានរបាយការណ៍សង្ខេបនៃសំណុំរឿង និងបានបញ្ជាក់ពីសិទ្ធិរបស់ជនជាប់ចោទ ប្រាប់ដល់សាមីខ្លួនព្រមទាំងចំណុចផ្សេងៗដែលជនជាប់ចោទ ត្រូវធ្វើនាពេលជំនុំជម្រះ ។



Scanned with CamScanner

៥-យល់ឃើញថា: នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted]ន បានឆ្លើយថា: ខ្លួនទទួលស្គាល់ចំពោះអង្គហេតុខាងលើ ប៉ុន្តែវាមានលក្ខណ:ធ្ងន់ធ្ងរពេក ។ ខ្លួនមិនបានធ្វើសកម្មភាពរំលោភសេពសន្ថវ:លើក្មេងទេ គឺខ្លួនបានត្រឹមតែប៉ះប្រដាក់នាង ហើយក៏មិនបានឱ្យនាងស្រាតខោអាវ [redacted] ប្រដាប់ភេទនាងនោះទេ ។ ជនរងគ្រោះគឺជាកូនចុងរបស់ខ្លួន មូលហេតុដែលនាំឱ្យមានការចោទប្រកាន់ខ្លួននោះមកពីខ្លួនទៅប៉ះប្រដាប់ភេទរបស់ជនរងគ្រោះ ។ ខ្លួនទទួលស្គាល់ចម្លើយដែលបានឆ្លើយនៅដំណាក់កាលសវនាការសាលាដំបូងខេត្តបន្ទាយមានជ័យ ដោយគ្មានការបង្ខិតបង្ខំនោះទេ ។ [redacted]

៦-យល់ឃើញថា: នាពេលសវនាការជនរងគ្រោះឈ្មោ[redacted]ចិន្តា ហៅ អាទី បានឆ្លើយថា: កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ ឈ្មោះ [redacted]វិន ដែលជាឪពុកចុងរបស់ខ្លួន បាន[redacted]ត់ ហើយគាត់បាន[redacted]ខ្លួន ដោយខ្លាចម្តាយខ្លួនមកទាន់ ក៏បញ្ឈប់សកម្មភាព ។ ក្រោយមកខណៈពេលម្តាយខ្លួនមិននៅផ្ទះ ពេលខ្លួនចូលបន្ទប់ទឹកឈ្មោះ លា វិន បានមកចាប់ស្រាតខោអាវរបស់ រួចបានយកប្រដាប់ភេទរបស់[redacted]ពេលនោះខ្លួនឈឺប្រដាប់ភេទជាខ្លាំង ។

៧-យល់ឃើញថា: នាពេលសវនាការដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted] ជុល បានឆ្លើយថា: កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២០ កូនស្រីរបស់ខ្លួនឈ្មោ[redacted]ចិន្តា ហៅ អាទី អាយុ១០ឆ្នាំ បាននិយាយប្រាប់ខ្លួនថាឈ្មោះ លា វិន (ប្តីចុងរបស់ខ្លួន) បានឱ[redacted] ហើយឈ្មោះ[redacted]វិន បានយ[redacted] ចូលប្រ[redacted]ចិន្តា ហៅ អាទី ចំនួនពីរលើក ខណៈខ្លួនកំពុងទៅធ្វើការបាត់ ។ លើកទី១ កាលអំឡុងខែឧសភា ឆ្នាំ២០២០ ឈ្មោះ [redacted] វិន បានហៅកូនស្រីខ្លួនឈ្មោះ [redacted]ចិន្តា ហៅ អាទី ឱ្យឡើងទៅលើឡៅតឿក្នុងផ្ទះ ហើយឱ្យកូនស្រីខ្លួ[redacted] និងបានយក[redacted]របស់កូនស្រីខ្លួនឈ្មោះ[redacted]ចិន្តា ហៅ អាទី ។ លើកទី២ ពេលកូនស្រីរបស់ខ្លួនឈ្មោះ[redacted]ចិន្តា ហៅ អាទី ចូលក្នុងបន្ទប់ទឹកឈ្មោះ [redacted]វិន ចូលទៅតាមហើយ[redacted]ចិន្តា ហៅ អាទី និងបា[redacted] កូ[redacted]ក្រោយពេលខ្លួនឮដូច្នេះក៏ទៅដាក់ពាក្យបណ្តឹងតែម្តង ។ សំណូមពរនៅក្នុងរឿងនេះខ្លួនមិនទាមទារសំណងទេ ។

៨-យល់ឃើញថា: នាពេលសវនាការតំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់ និងសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

០៩-យល់ឃើញថា: នាពេលសវនាការមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោ[redacted] ទិន បានធ្វើសេចក្តីសន្និដ្ឋានស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាកែប្រែបទចោទ ទៅជាបទ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ វិញ តាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងបន្ធូរបន្ថយទោសឱ្យកូនក្តីរបស់ខ្លួនផង ។

១០-យល់ឃើញថា: ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណីអ្នកទទួលខុសត្រូវរដ្ឋប្បវេណី សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងមហាអយ្យការ និងភស្តុតាងនានាក្នុងសំណុំរឿង ក្រុមប្រឹក្សាជំនុំជម្រះ យល់ឃើញថា: ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ បានឆ្លើយបញ្ជាក់ថារូបពិតធ្វើសកម្មភាពរួមភេទជាមួយជនរងគ្រោះប្រាកដមែន តែមិនបានសម្រេចនោះ



Scanned with CamScanner

ទេ ដោយមូលហេតុថាដាក់ប្រដាប់ភេទមិនចុះក្នុងទ្វាមាសរបស់ជនរងគ្រោះ និងខ្លាចប្រពន្ធរបស់គេមកទាន់ទើបបញ្ឈប់សកម្មភាពនោះទៅវិញ ហេតុដូច្នេះគប្បីក្រុមប្រឹក្សាជំនុំជម្រះ សម្រេចតម្កល់សេចក្តីសម្រេចរបស់សាលាដំបូងទុកជាបានការដដែល ។

ចំពោះសកកម្មភាពប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទ គឺឡើងដោយសារមូលហេតុនៃកម្រិតចំណេះដឹងរបស់គេមានលក្ខណៈទាប ហើយថ្វីត្បិតតែសកម្មភាពរបស់ជាប់ចោទខាងលើនេះ ជាបទល្មើសដែលមានស្ថានទម្ងន់ដោយសារតែឋានៈរបស់ជនជាប់ចោទ (ដែលជាឪពុកចុងរបស់ជនរងគ្រោះ) ប៉ុន្តែសកម្មភាពរបស់ជនជាប់ចោទពុំបានបង្ហាញពីចរិតលក្ខណៈឃោរឃៅ ទៅលើជនរងគ្រោះឡើយ ម្យ៉ាងវិញព្យសនកម្មដែលបានកើតឡើងដោយផ្ទាល់ចំពោះជនរងគ្រោះពុំមានលក្ខណៈធ្ងន់ធ្ងរទឡើយ ហេដូច្នេះគប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណាអំពីស្ថានសម្រាលចំពោះជននេះដោយសារតែស្ថានភាពកម្រិតវប្បធម៌ទាប ហើយជនជាប់ចោទរូបនេះគឺជាកម្លាំងមួយដ៏ចម្បងក្នុងការទ្រទ្រង់ជីវភាពក្នុងគ្រួសារ ដែលត្រូវចិញ្ចឹមបីបាច់ថែរក្សា ។

១១-យល់ឃើញថាៈ សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលបានសម្រេចសេចក្តីចំពោះចំណុចទាំងមូល នៃបណ្តឹងឧទ្ធរណ៍របស់ [redacted] ពុំទាន់មានលក្ខណៈត្រឹមត្រូវនោះទេ ហេតុដូច្នេះ គប្បីក្រុមប្រឹក្សាសម្រេចកែប្រែសេចក្តីសម្រេចជាថ្មី ដោយផ្អែកតាមមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ សម្រេច

១.កែប្រែចំណុចទី១ នៃសាលក្រមព្រហ្មទណ្ឌលេខៈ ១២៣ (គ)/១០៧៥ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

២.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ដាក់ពន្ធនាគារកំណត់ ០៨ (ប្រាំបី) ឆ្នាំ ពីបទ រំលោភសេពសន្ថវៈស្ថានទម្ងន់ទោស (ដោយមូលហេតុអាយុជនរងគ្រោះ) ប្រព្រឹត្តនៅភូមិក្បាលស្ពាន២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងខែឧសភា ឆ្នាំ២០២០ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣៩ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ រក្សាសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| [redacted] | [redacted] | [redacted] | [redacted] |



Scanned with CamScanner